# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) |
| **ដាក់ទៅ** | ៖ | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | ៖ | ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | ៖ | អោ អាន |
| **ភាសាដើម** | ៖ | អង់គ្លេស |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Feb-2020, 12:05
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖** សម្ងាត់

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ៖**

**ហត្ថលេខា៖**

---

## ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង

---

**អ្នកដាក់ឯកសារ៖**

**សហមេធាវី**

មុំ លុដ្ឋ

Richard ROGERS

Göran SLUITER

**ផ្ញើរជូន៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម Kang Jin BAIK

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda J. Hollis

**អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

# សេចក្ដីផ្ដើម

1. តាមរយៈសហមេធាវីរបស់គាត់ (*"មេធាវីការពារក្ដី"*) លោក អោ អាន សូមឆ្លើយតបទៅនឹង *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* (*"សំណើសុំចាត់វិធានការរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ"*)[1] និងសូមលើកឡើងថាឧបាស្រ័យដែលបានស្នើសុំដោយ សហព្រះរាជអាជ្ញាអន្តរជាតិ មិនត្រូវបានអនុញ្ញាតដោយក្របខណ្ឌគតិយុត្តិរបស់អង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ទេ។ សហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញសំណើរបស់ ខ្លួនជាបញ្ហារដ្ឋបាលធម្មតា។ តាមការពិតគាត់កំពុងស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាឡើងវិញ ទៅលើសេចក្ដីសម្រេចរបស់ខ្លួនស្ដីពីអានុភាពគតិយុត្ត និងផលវិបាកផ្នែកនីតិវិធីនៃដីកាដំណោះ ស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា។

2. មេធាវីការពារក្ដីសូមអះអាងសាជាថ្មីនូវជំហររបស់ខ្លួនថា សំណុំរឿង ០០៤/២ មិនអាចបញ្ជូនទៅ អង្គជំនុំជម្រះសាលាដំបូងបានទេ ដោយសារអង្គជំនុំជម្រះមិនបានទទួលយកសំណុំរឿងនេះទៅ ពិនិត្យតាមផ្លូវច្បាប់ទេ។ នៅក្នុង *សំណើសុំចាត់វិធានការ* របស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងដោយមិនត្រឹមត្រូវថា "គោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់នេះ" គឺថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្ដឹង "ដោយស្វ័យប្រវត្តិ" អំពីសំណុំរឿងនេះ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៩[2]។ ក្នុងការអះអាងបែបនេះ គាត់យល់ច្រឡំសំអាងហេតុរបស់ អង្គបុរេជំនុំជម្រះ ចំពោះ ការធ្វើសេចក្ដីសន្និដ្ឋានថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាជារឿងខុសច្បាប់ ជាមួយនឹង ការកំណត់អំពីអានុភាពគតិយុត្ត និងផលវិបាកផ្នែកនីតិវិធីនៃការធ្វើសេចក្ដីសន្និដ្ឋាននោះ។ តាម ការពិតអង្គបុរេជំនុំជម្រះ ពុំទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ដើម្បីសម្រេចទៅលើផល វិបាកនៃសកម្មភាពខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេតទេ គឺសហចៅក្រមបានធ្វើសេចក្ដី សន្និដ្ឋានផ្ទុយគ្នា[3]។

---

[1] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់រាល់វិធាន ការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* (*"សំណើសុំចាត់ វិធានការរបស់សហព្រះរាជអាជ្ញាអន្តរជាតិ"*) ឯកសារ **D359/25** ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០។

[2] *សំណើសុំចាត់វិធានការរបស់ ស.ព.អ* កថាខណ្ឌ ២៣។

[3] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ដំណោះស្រាយ* (*"សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍"*) ឯកសារ **D359/24 និង D360/33** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ កថា ខណ្ឌ ១២៤, ១៧០-៣០២, ៣០៤-៣២៩។

3. សហព្រះរាជអាជ្ញាអន្តរជាតិ ក៏មិនអើពើចំពោះអង្គហេតុដែលមិនអាចប្រកែកបានថា សហចៅក្រមស៊ើបអង្កេតជាតិបានចេញ *ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន* (*"ដីកាសម្រេចលើកលែងចោទប្រកាន់"*)[4] ហើយថា ដីកាសម្រេចនេះមិនត្រូវបានច្រានចោលដោយសំឡេងគាំទ្រភាគច្រើនលើសលប់ នៅក្នុងពេលសម្រេចទៅលើបណ្តឹងឧទ្ធរណ៍នោះទេ។ ផ្ទុយទៅវិញ ចៅក្រមភាគច្រើននៅ អង្គបុរេជំនុំជម្រះ បានតម្កល់*ដីកាសម្រេចលើកលែងចោទប្រកាន់*[5] ហើយថា ដីកានេះ គឺជាដីកាដែលមានសុពលភាពអនុវត្ត អនុលោមតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង។ ការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង (ក្នុងខណៈដែលសំណុំរឿងនេះត្រូវបានច្រានចោលដោយប្រសិទ្ធភាព) ជាការរំលោភលើក្របខណ្ឌគតិយុត្តិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ទន្ទឹមករណីដែលថា *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*[6] ក៏នៅមានសុពលភាពដែរ អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង មិនមានឥទ្ធិពលលើការពិតដែលថា *ដីកាសម្រេចលើកលែងចោទប្រកាន់* បានបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ រួចទៅហើយ។ ចៅក្រមភាគតិចនៃអង្គបុរេជំនុំជម្រះ មិនអាចបដិសេធសេចក្តីសម្រេចនោះ ឬបង្គាប់ជាឯកតោភាគីដល់ក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ ឱ្យបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងបានឡើយ[7]។

4. ដូចបានសម្រេចដោយចៅក្រមភាគច្រើននៅ អង្គបុរេជំនុំជម្រះ គឺថា ពុំមានវិធាន ឬយន្តការតាមផ្លូវច្បាប់ណាមួយ ដើម្បីដោះស្រាយស្ថានភាពគតិយុត្តិដ៏លំបាកមិនធ្លាប់មានពីមុនមក តួយ៉ាងដូចជាការមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាលើកលែងចោទប្រកាន់នៅក្នុងសំណុំរឿងតែមួយ និងទៅលើបទចោទដូចគ្នា ហើយពុំបានទទួលសេចក្តីសម្រេចនៅបណ្តឹងឧទ្ធរណ៍ឡើយ។ អនុលោមតាមគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (*"រដ្ឋធម្មនុញ្ញកម្ពុជា"*) និង មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (*'ICCPR'*) វិមតិសង្ស័យដែលកើតបែបឡើងនេះត្រូវតែដោះស្រាយជាប្រយោជន៍ដល់ អោ អាន។

---

[4] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស *ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន* (*"ដីកាសម្រេចលើកលែងចោទប្រកាន់"*) ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[5] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១៧០-៣០២។

[6] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ **D360** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[7] *សំណើសុំចាត់វិធានការរបស់ ស.ព.អ* កថាខណ្ឌ ២៤។

5. ហេតុនេះ អង្គបុរេជំនុំជម្រះ ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការបដិសេធសំណូមពរដែលបានស្នើសុំដោយ សហព្រះរាជអាជ្ញាអន្តរជាតិ។ សំណុំរឿងនេះមិនអាចបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងបានទេ ដោយសារអង្គជំនុំជម្រះមិនបានទទួលយកសំណុំរឿងយកមកពិនិត្យតាមផ្លូវច្បាប់ទេ។ រដ្ឋធម្មនុញ្ញកម្ពុជាកំណត់ថា សំណុំរឿង ០០៤/២ ត្រូវបានបញ្ចប់ជាក់ស្តែងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

6. មេធាវីការពារក្តីសូមដាក់ចម្លើយតបនេះជាភាសាអង់គ្លេសមុនសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើបាន។

## ប្រវត្តិនីតិវិធី

7. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា នៅក្នុងសំណុំរឿង ០០៤/២[8]។

8. នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិបានដាក់សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*[9]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង *ដីកាសម្រេចលើកលែងចោទប្រកាន់*[10]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ផងដែរ មេធាវីការពារក្តីបានដាក់សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*[11]។

9. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* (*"សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍"*)។ អង្គជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាជារឿងខុសច្បាប់ ហើយអង្គជំនុំជម្រះ

---

[8] *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*។ *ដីកាសម្រេចលើកលែងចោទប្រកាន់*។

[9] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អជប៦០) *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងសំណុំរឿង ០០៤/២* ឯកសារ **D360/8/1** ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨។

[10] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អជប៦០) *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359)* (*"បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ"*) ឯកសារ **D359/3/1** ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។

[11] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អជប៦០) *បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤/២* (*"បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"*) ឯកសារ **D360/5/1** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨។

មិនអាចរកបានសំឡេងភាគច្រើនលើសលប់ ដើម្បីសម្រេចទៅលើអង្គសេចក្តីនៃសារណាបណ្តឹងឧទ្ធរណ៍របស់ភាគីបានឡើយ[12]។

10. នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ មេធាវីការពារក្តីបានផ្ញើលិខិតមួយច្បាប់ទៅអង្គជំនុំជម្រះសាលាដំបូង ដោយស្នើសុំការបញ្ជាក់ថា អង្គជំនុំជម្រះមិនបានទទួលយកសំណុំរឿង ០០៤/២ មកពិនិត្យតាមផ្លូវច្បាប់ទេ ហើយជាជម្រើសម្យ៉ាងទៀត ស្នើសុំពន្យារពេលវេលា និងការណែនាំសម្រាប់ដាក់អញ្ញត្រកម្ម អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[13]។

11. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ *សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ជាមួយឧបសម្ព័ន្ធសម្ងាត់ ក អនុលោមតាមវិធាន ៨០*[14] ជាឯកសារក្រដាសទៅអង្គភាពគ្រប់គ្រងតុលាការ។

12. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ ដោយសារអង្គជំនុំជម្រះសាលាដំបូងនៅតែមិនអាចទទួលយកសំណុំរឿងមកពិនិត្យតាមផ្លូវច្បាប់បាន មេធាវីការពារក្តីបានដាក់ *សេចក្តីសង្ខេបអញ្ញត្រកម្មរបស់ អោ អាន អនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង* របស់ខ្លួនជាឯកសារក្រដាសទៅអង្គភាពគ្រប់គ្រងតុលាការ ដើម្បីរក្សាសិទ្ធិរបស់ អោ អាន[15]។

13. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានផ្ញើអ៊ីមែលទៅភាគីទាំងអស់ដោយលើកឡើងថា អង្គបុរេជំនុំជម្រះ មិនទាន់បានបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ[16]។

14. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ដោយដឹងជាម្តងទៀតថាអង្គជំនុំជម្រះសាលាដំបូងនៅតែមិនបានទទួលយកសំណុំរឿងមកពិនិត្យតាមផ្លូវច្បាប់ មេធាវីការពារក្តីបានដាក់ *សារណាស្តីពីបញ្ជីឈ្មោះ*

---

[12] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១២៤, ១៦៩។

[13] ក្រុមមេធាវីការពារក្តី អោ អាន *"សំណើសុំការបញ្ជាក់ថា អង្គជំនុំជម្រះមិនអាចទទួលយកសំណុំរឿង ០០៤/២ មកពិនិត្យតាមផ្លូវច្បាប់បាន ជាជម្រើសម្យ៉ាងទៀត សំណើសុំការពន្យារពេល និងការណែនាំសម្រាប់ការដាក់អញ្ញត្រកម្ម អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង"* ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។

[14] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ *សារណាស្តីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ជាមួយឧបសម្ព័ន្ធសម្ងាត់ ក អនុលោមតាមវិធាន ៨០ របស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។

[15] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ *សេចក្តីសង្ខេបអញ្ញត្រកម្មរបស់ អោ អាន អនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០។

[16] អ៊ីម៉ែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះទៅភាគីអំពីសំណុំរឿង ០០៤/០២ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០២០, មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១។

*សាក្សី និងអ្នកជំនាញ ជាមួយឧបសម្ព័ន្ធសម្ងាត់ ១ អនុលោមតាមវិធាន ៨០ និង ចម្លើយតបរបស់គាត់ទៅនឹងសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ជាមួយឧបសម្ព័ន្ធសម្ងាត់ ក អនុលោមតាមវិធាន ៨០* ជាឯកសារក្រដាសទៅអង្គភាពគ្រប់គ្រងតុលាការ ដើម្បីរក្សាសិទ្ធិរបស់ អោ អាន[17]។

15. នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ជាឯកសារក្រដាសទៅអង្គភាពគ្រប់គ្រងតុលាការ។ គាត់ក៏បានដាក់ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើដល់អង្គជំនុំជម្រះសាលាដំបូងចាត់វិធានការដើម្បីបានសិទ្ធិទទួលចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងនៃសំណុំរឿង ០០៤/០២ (អោ អាន)*[18]។

16. នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានផ្ញើអ៊ីមែលបន្ថែមទៅភាគីទាំងអស់ដោយអះអាងសាជាថ្មីថា អង្គបុរេជំនុំជម្រះមិនទាន់បានបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ[19]។

## ច្បាប់ជាធរមាន

17. វិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុងចែងថា ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ *ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ* សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវតម្កល់ទុកជាបានការ។

18. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ គោលការណ៍ដូចគ្នានេះត្រូវបានទទួលយកជាសាកលដោយមានចែងនៅក្នុងមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

19. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ មានចែងនៅក្នុងមាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាង

---

[17] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/អជសជ *សារណាស្តីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ជាមួយឧបសម្ព័ន្ធសម្ងាត់ ក អនុលោមតាមវិធាន ៨០ និង ចម្លើយតបរបស់គាត់ទៅនឹងសារណាស្តីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ជាមួយឧបសម្ព័ន្ធសម្ងាត់ ក អនុលោមតាមវិធាន ៨០ របស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

[18] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/អជសជ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើដល់អង្គជំនុំជម្រះសាលាដំបូងចាត់វិធានដើម្បីទទួលបានសិទ្ធិចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុះជម្រះ និងសំណុំរឿងនៃសំណុំរឿង ០០៤/០២ (អោ អាន)* ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០។

[19] អ៊ីម៉ែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះអំពីសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នាថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០២០ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០២០ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២។

អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដែលកិច្ចព្រមព្រៀងនេះធ្វើឡើងនៅ រាជធានីភ្នំពេញ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ និង មាត្រា ៣៣ ដល់ ៣៥*ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ និង វិធាន ២១ នៃវិធានផ្ទៃក្នុង[20]។

## ចម្លើយតប

20. សំណូមពរដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើសុំមិនត្រូវបានអនុញ្ញាតនៅក្នុងក្របខណ្ឌគតិយុត្តិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ និងត្រូវតែបដិសេធចោល។ សំណុំរឿង ០០៤/០២ ត្រូវបានច្រានចោលជាក់ស្តែងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ហើយអង្គជំនុំជម្រះសាលាដំបូងមិនបានទទួលយកសំណុំរឿង ០០៤/០២ មកពិនិត្យតាមផ្លូវច្បាប់ទេ។ សំណុំរឿងមិនអាចបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងដោយពុំមានការពិចារណាឱ្យបានពេញលេញ និងសំឡេងភាគច្រើនលើសលប់នៅអង្គបុរេជំនុំជម្រះ ដើម្បីគាំទ្រដល់ការបញ្ជូនសំណុំរឿងនោះឡើយ។

21. សហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញសំណើរបស់ខ្លួនថាជា "វិធានការផ្នែករដ្ឋបាលធម្មតា"[21]។ តាមការពិត គាត់កំពុងស្នើសុំឱ្យ អង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចរបស់ខ្លួនអំពីអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ និងអានុភាពគតិយុត្តិនៃដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា[22]។ ទោះបីអង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះ

---

[20] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ រាជធានីភ្នំពេញ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ មាត្រា ១៣។ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានធ្វើវិសោធនកម្មនៅ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/២០០៦) មាត្រា ៣៣, ៣៥ *ថ្មី*។ វិធាន ២១ នៃវិធានផ្ទៃក្នុង។

[21] *សំណើសុំចាត់វិធានការរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២៣-២៤។

[22] ភាគីដែលស្នើសុំការពិចារណាឡើងវិញត្រូវបំពេញទៅតាមបទដ្ឋានខ្ពស់ ដែលសហព្រះរាជអាជ្ញាអន្តរជាតិមិនបានធ្វើនៅក្នុង *សំណើសុំចាត់វិធានការ* ទេ។ ការពិចារណាឡើងវិញគឺជាវិធានការនៃឆន្ទានុសិទ្ធិដែលអនុវត្តតែចំពោះករណីលើកលែងដែលមានលេចឡើងនូវការប្រែប្រួលកាលៈទេសៈ ដែលបណ្តាលឱ្យសេចក្តីសម្រេចពីមុនមានកំហុស ឬបណ្តាលឱ្យមានភាពអយុត្តិធម៌។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ០៣) *សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់សើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង* ឯកសារ C22/I/68 ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ២៥-២៨ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣ (អង្គបុរេជំនុំជម្រះបានពិពណ៌នាអំពីបទដ្ឋានសម្រាប់ការពិចារណា

ស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាជារឿងខុសច្បាប់ក៏ដោយ[23] តែអង្គជំនុំជម្រះមិនទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ដែលសម្រេចទៅលើអានុភាពនៃភាពខុសច្បាប់នេះ និងផលវិបាកផ្នែកនីតិវិធីសម្រាប់សំណុំរឿង ០០៤/០២ ទេ។ ចៅក្រមភាគច្រើននៅ អង្គបុរេជំនុំជម្រះបានសម្រេចថា គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញតម្រូវឱ្យច្រានចោលសំណុំរឿង ០០៤/០២[24]។ ចៅក្រមភាគតិចនៅអង្គបុរេជំនុំជម្រះមិនអាចបដិសេធសេចក្តីសម្រេចនោះ ឬបង្គាប់ជាឯកត្តោភាគីដល់ក្រឡាបញ្ជីអង្គបុរេជំនុំជម្រះឱ្យបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងបានឡើយ[25]។

22. សហព្រះរាជអាជ្ញាអន្តរជាតិ បានជំទាស់ដោយមិនត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងទទួលយកសំណុំរឿង ០០៤/០២ ទៅពិនិត្យដោយស្វ័យប្រវត្តិ ដោយផ្អែកលើមូលដ្ឋាននៃ "គោលជំហរស្វ័យប្រវត្តិ" *គឺ*ថា ក្នុងករណីខ្វែងយោបល់ដែលមិនបានដោះស្រាយរវាងសហចៅក្រមស៊ើបអង្កេតកិច្ចស៊ើបសួរនឹងបន្ត[26]។ ចំណុចនេះមិនត្រឹមត្រូវទេ ដោយសារ៖ (ក) សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់យន្តការទាំងអស់ដែលមានដើម្បីដោះស្រាយករណីខ្វែងយោបល់គ្នា រួមទាំង "គោលជំហរស្វ័យប្រវត្តិ" ផងដែរ ដោយចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា[27] (ខ) អង្គបុរេជំនុំជម្រះ មិនទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ ដើម្បីសម្រេចទៅលើអានុភាពគតិយុត្តិនៃការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នាដែលខុសច្បាប់ និងផល

---

ឡើងវិញដូចតទៅ៖ "អង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិដោយឯកឯង ក្នុងការពិចារណាសេចក្តីសម្រេចបន្ទាន់បង្ខំដែលបានចេញកាលពីលើកមុន សាជាថ្មី នៅក្នុងករណីពិសេស "ប្រសិនបើមានកំហុសចំពោះអំណះអំណាងច្បាស់លាស់ ឬ ប្រសិនបើចាំបាច់ក្នុងការរារាំងភាពអយុត្តិធម៌""។) (ដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Milutinovic *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-87-T *សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំឱ្យពិចារណាសាជាថ្មីលើសេចក្តីសម្រេចស្តីពីសំណើរបស់រដ្ឋអាជ្ញាសុំវិធានការការពារបន្ថែម នៅក្នុងដំណាក់កាលជំនុំជម្រះ ដើម្បីការពារសាក្សី K56* ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ២)។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Mucic និងអ្នកផ្សេងទៀត *សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះការផ្តន្ទាទោស* សំណុំរឿងលេខ IT-96-21-A *bis* ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៣ កថាខណ្ឌ ៤៩ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Bagosora និងអ្នកផ្សេងទៀត *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំពីការបដិសេធមិនពិចារណាសាជាថ្មីពាក់ព័ន្ធនឹងវិធានការការពារ និងពាក្យសុំការប្រកាសពី "កង្វះយុត្តាធិការ"* សំណុំរឿងលេខ ICTR-98-41-A ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០២ កថាខណ្ឌ ១០ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥។

[23] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១២៣-១២៤។

[24] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ២៩៥-៣០២។

[25] *សំណើសុំចាត់វិធានការរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២៤។

[26] *សំណើសុំចាត់វិធានការរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២៣, ២៥-២៦។

[27] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១២១។

វិបាករបស់វា[28] និង (គ) អនុលោមតាមវិធាន ៧៣(១៣)(ក) នៃវិធានផ្ទៃក្នុង *ដីកាសម្រេចលើកលែងចោទប្រកាន់* តម្កល់ទុកជាបានការ និងមិនរងផលប៉ះពាល់ដោយសារបណ្តឹងឧទ្ធរណ៍ឡើយ។

23. អង្គបុរេជំនុំជម្រះ បានសម្រេចជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយពីរជារឿងខុសច្បាប់[29]។ ចំណុចសំខាន់នៃការផ្តល់សំអាងហេតុរបស់ខ្លួនគឺការបង្ហាញថា ដីកាដំណោះស្រាយត្រូវបញ្ចប់ការស៊ើបអង្កេតជាស្ថាពរ ហើយថារាល់ករណីខ្វែងយោបល់ទាំងអស់លើបញ្ហានេះត្រូវដោះស្រាយតាមរយៈនីតិវិធីដោះស្រាយករណីខ្វែងយោបល់អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ឬដោយ "គោលជំហរស្វ័យប្រវត្តិ"[30]។ បើតាមអង្គបុរេជំនុំជម្រះ ការមិនសំអាងទៅលើក្របខណ្ឌគតិយុត្តិនោះ សហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យប៉ះពាល់ដល់ "គោលជំហរស្វ័យប្រវត្តិ"[31] ដោយបានជ្រើសរើសចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ដែលខុសច្បាប់ទៅវិញ។

24. ជាការសំខាន់ អង្គបុរេជំនុំជម្រះ មិនទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ដើម្បីសម្រេចទៅលើអានុភាពនៃភាពខុសច្បាប់ ឬទៅលើផលវិបាកផ្នែកនីតិវិធីរបស់វាទេ[32]។ មានតែចៅក្រមភាគតិចប៉ុណ្ណោះដែលបានសម្រេចថាសំណុំរឿងនេះគួរបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[33]។ ចៅក្រមភាគច្រើនបានសម្រេចថា សំណុំរឿងនេះគួរត្រូវបានច្រានចោល[34]។

25. ជាងនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិ ក៏មិនអើពើពីអង្គហេតុជាក់ស្តែងដែលថាសហចៅក្រមស៊ើបអង្កេតជាតិ បានចេញ *ដីកាសម្រេចលើកលែងចោទប្រកាន់* (មុន *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*)[35] ហើយដីកានេះមិនត្រូវច្រានចោលដោយសំឡេងគាំទ្រភាគច្រើនលើស

---

[28] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១២៤, ១៧០-៣០២, ៣០៤-៣២៩។

[29] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១២៣-១២៤។

[30] "គោលជំហរស្វ័យប្រវត្តិ" ត្រូវបានកំណត់និយមន័យថា៖ ប្រសិនបើ "ចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះ ត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំ [...] ឲ្យដោះស្រាយការខ្វែងគំនិតនេះ"។ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១១១។

[31] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១២១។

[32] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១២៤, ១៧០-៣០២, ៣០៤-៣២៩។

[33] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ៦៩៤។

[34] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ៣០២។

[35] *ដីកាសម្រេចលើកលែងចោទប្រកាន់* ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង និងបានចុះលេខជាឯកសារ D359។ ការដាក់បញ្ចូលឯកសារនេះធ្វើឡើងមុនពេលចេញ *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ដែលបានចុះលេខជាឯកសារ D360។ ទោះបីអង្គហេតុនេះហាក់ដូចជាតូចតាច តែវាធ្វើឲ្យការមិនអើពើទាំងស្រុងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពីអត្ថិភាពនៃ*ដីកា*

លប់ នៅក្នុងពេលសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ឡើយ។ ការពិត *ដីកាសម្រេចលើកលែងចោទប្រកាន់* បានទទួលប្រយោជន៍ពីចៅក្រមភាគច្រើនយ៉ាងច្បាស់លាស់ និងការគាំទ្រពី សហព្រះរាជអាជ្ញាជាតិ។ អនុលោមតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង ប្រសិនបើមិនទទួលបានសំឡេងគាំទ្រភាគច្រើនចាំបាច់ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ក្រៅពីដីកាបញ្ជូនរឿងទៅជំនុំជម្រះទេនោះ ដីកានោះនឹងនៅមានសុពលភាពដដែល។ ហេតុនេះ *ដីកាសម្រេចលើកលែងចោទប្រកាន់*របស់សហចៅក្រមស៊ើបអង្កេតជាតិ មិនត្រូវទទួលរងផលប៉ះពាល់ដោយបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទេ។ អត្ថិភាពនៃ "គោលជំហរស្វ័យប្រវត្តិ" ដើម្បីគ្រប់គ្រងករណីខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត មុនពេលចេញសេចក្តីសម្រេចនោះ មិនអាចយកមកសំអាងដើម្បីបំបាត់ ឬមិនអើពើពី*ដីកាសម្រេចលើកលែងចោទប្រកាន់* ដែលមានសុពលភាពអនុវត្តបានឡើយ។

26. ចុងក្រោយ ទឡ្ហីករណ៍ដែលថា *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ក៏អាចមានសុពលភាពដែរ អនុលោមតាម វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង មិនមានឥទ្ធិពលទៅលើអង្គហេតុដែលថា *ដីកាសម្រេចលើកលែងចោទប្រកាន់* បានបញ្ចប់កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៤/០២ នោះឡើយ។ ដូចដែលចៅក្រមភាគច្រើននៅអង្គបុរេជំនុំជម្រះ បានបញ្ជាក់រួចមកហើយ គឺថាក្របខណ្ឌគតិយុត្តិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចដោះស្រាយភាពជាប់គាំង ដោយសារតែការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ដែលពុំមានដីកាណាមួយ ក្នុងចំណោមដីកាទាំងពីរនោះត្រូវបានបដិសេធដោយសំឡេងគាំទ្រភាគច្រើនលើសលប់ នៅក្នុងពេលសម្រេចទៅលើបណ្តឹងឧទ្ធរណ៍នោះទេ[36]។ អនុលោមតាមគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រាល់ការជាប់គាំង និងភាពមិនច្បាស់លាស់ទាំងអស់ត្រូវដោះស្រាយជាប្រយោជន៍ដល់ អោ អាន។ *ដីកាសម្រេចលើកលែងចោទប្រកាន់* ដែលទទួលប្រយោជន៍ពីការគាំទ្រដោយចៅក្រមភាគច្រើន និងសហព្រះរាជអាជ្ញាជាតិនោះ ត្រូវមានអាទិភាពទៅលើ *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*។

27. លទ្ធផលនេះជាការពិតមិនអាចប្រកែកបានផងដែរ ពាក់ព័ន្ធនឹងសិទ្ធិរបស់ អោ អាន អនុលោមតាម

*សម្រេចលើកលែងចោទប្រកាន់* កាន់តែមានភាពធ្ងន់ធ្ងរ។

[36] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ២៩៥-៣០២។

មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងការទទួលបាន "សាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង *ដែលបង្កើតឡើងដោយច្បាប់*"។ អនុលោមតាមយុត្តិសាស្ត្រអន្តរជាតិ សាលាក្តី"ដែលបង្កើតឡើងដោយច្បាប់" មិនមែនជាបញ្ហាទម្រង់ប៉ុណ្ណោះទេ[37] តែផ្ទុយទៅវិញ ច្បាប់ពាក់ព័ន្ធត្រូវស្របទៅនឹងលក្ខណៈវិនិច្ឆ័យពីគុណភាពជាក់លាក់ រួមទាំង ការគោរពដល់បទដ្ឋាននៃដំណើរការតាមច្បាប់ជាមូលដ្ឋាន[38]។ ប្រព័ន្ធច្បាប់មួយដែលមិនអើពើចំពោះជំហររបស់ចៅក្រមភាគច្រើន ជាពិសេសនៅពេលពុំមានក្របខណ្ឌគតិយុត្តិច្បាស់លាស់ពាក់ព័ន្ធនឹងអ្វីដែលគួរនឹងកើតឡើងនាពេលបន្ទាប់នោះ មិនបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនោះទេ[39]។ វាអាចពុំមានវិមតិសង្ស័យឡើយដែលថាស្ថានភាពបច្ចុប្បន្នដែល សហព្រះរាជអាជ្ញាអន្តរជាតិ មានបំណងមិនអើពើចំពោះ*ដីកាសម្រេចលើកលែងចោទប្រកាន់* ដែលគាំទ្រដោយចៅក្រមភាគច្រើន ហើយបន្តកិច្ចដំណើរការនីតិវិធីនោះ មិនគោរពដល់ដំណើរការត្រឹមត្រូវតាមច្បាប់ជាមូលដ្ឋាន និងជាការបំផ្លាញដល់សាលាក្តីមានសមត្ថកិច្ចដែលបង្កើតឡើងដោយច្បាប់។

28. អនុលោមតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ សំណុំរឿង ០០៤/២ មិនអាចបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងបានទេ ដោយសារសំណុំរឿងនេះត្រូវបានច្រានចោលនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ហើយអង្គជំនុំជម្រះសាលាដំបូងមិនបានទទួលយកសំណុំរឿងនេះទៅពិនិត្យស្របច្បាប់

[37] គណៈកម្មាធិការសិទ្ធិមនុស្ស (*'HRC'*) យោបល់ទូទៅលេខ ៣៤ មាត្រា ១៤៖ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ និងសាលាក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ឯកសារអង្គការសហប្រជាជាតិ លេខ CCPR/C/GC/32 (ឆ្នាំ ២០០៧) កថាខណ្ឌ ១៨ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦។

[38] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Karadžić សំណុំរឿងលេខ IT-95-5/18-T *សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទជំទាស់ទៅនឹងសុពលភាពគតិយុត្តិ និងភាពស្របច្បាប់របស់សាលាក្តី* ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ១៣ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧ ("[...] តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវ "បានបង្កើតឡើងដោយច្បាប់" នៅពេលដែលមាន មាន""ប្រភពពីវិធាននៃច្បាប់ និងផ្តល់ការធានាទាំងអស់ដែលមានកំណត់នៅក្នុងលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ"") (ដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Tadić សំណុំរឿងលេខ IT-94-1-AR72 *សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំប្តឹងឧទ្ធរណ៍បន្ទាន់បង្អំទៅលើយុត្តាធិការ* ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ១០-១២)។ *រឿងក្តី* Richert *ទល់នឹង ប្រទេសប៉ូឡូញ* តុលាការ ECtHR ពាក្យសុំលេខ 54809/07 *សាលដីកា* ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ៤៣ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨ ("សាលាក្តីមួយដែលត្រូវបានបង្កើតឡើងដោយច្បាប់ ត្រូវបំពេញទៅលើលក្ខខណ្ឌមួយចំនួនដូចជាឯករាជ្យភាពពីសមាជិក និងចិរវេលានៃមុខតំណែងរបស់សមាជិក ភាពមិនលម្អៀង និងអត្ថិភាពនៃការការពារផ្នែកនីតិវិធី")។

[39] មេធាវីការពារក្តីទទួលស្គាល់ថា ស្ថានភាពបច្ចុប្បន្នពុំធ្លាប់មានពីមុនមកទេ ហើយក៏មិនស្ថិតក្នុងករណីវិវាទនៅឯយន្តការសិទ្ធិមនុស្សអន្តរជាតិណាមួយដែរ។ យុត្តិសាស្ត្រសិទ្ធិមនុស្សអន្តរជាតិបានផ្តោតយ៉ាងទូលំទូលាយទៅលើភាពមិនស្របច្បាប់នៃតុលាការយោធាពិសេស ឬគណៈកម្មការដែលត្រូវបានបង្កើតឡើង ក្នុងគោលបំណងជួយសម្រួលជាពិសេសដល់ការផ្តន្ទាទោស។ *សូមមើល* HRC យោបល់ទូទៅលេខ ៣២ កថាខណ្ឌ ២២។

ទេ។ សហព្រះរាជអាជ្ញាអន្តរជាតិ កំពុងព្យាយាមពណ៌នាថា ស្ថានភាពបច្ចុប្បន្នជាបញ្ហា "រដ្ឋបាល" ទោះបីវាជាបញ្ហានីត្យានុកូលភាពក៏ដោយ។

## **សេចក្តីសន្និដ្ឋាន និង សំណើ**

29. មេធាវីការពារក្តីស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះ មេត្តាបដិសេធសំណូមពរដែលបានស្នើសុំដោយសហព្រះរាជអាជ្ញាអន្តរជាតិ។ សំណុំរឿង ០០៤/០២ ត្រូវបានបញ្ចប់ជាក់ស្តែងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ហើយអង្គជំនុំជម្រះសាលាដំបូងមិនបានទទួលយកសំណុំរឿងនេះទៅពិនិត្យស្របច្បាប់ទេ។ យោងទៅតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ ការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង នឹងរំលោភបំពានលើក្របខណ្ឌគតិយុត្តិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅលើគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងទៅលើសិទ្ធិរបស់ អោ អាន ដែលទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដោយសាលាក្តីមានសមត្ថកិច្ចដែលបង្កើតឡើងដោយច្បាប់។

សូមលោកចៅក្រមមេត្តាទទួលយកចម្លើយតបនេះដោយក្តីគោរពពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២០

**សហមេធាវីការពារក្តី អោ អាន**

| មុំ លុជ្ស | Richard ROGERS | Göran SLUITER |
|---|---|---|